សង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង និតិសម្បទា ព្រមទាំងរដ្ឋមន្ត្រីនៃបណ្តាក្រសួង និង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៥២ អនក្រ.បក

## ស្តីពីការបង្កើតអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សារំសាយ កងកំលាំងប្រដាប់អាវុធ

***

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- តាមសំណើរបស់ប្រធាន ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

## សំរេច

## ជំពូក ១

## អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ

មាត្រា ១ ._ ត្រូវបានបង្កើត អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ ដែលមានស្វ័យភាពរដ្ឋបាល ។

មាត្រា ២ ._ អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ សមាសភាពដូចតទៅ :

-ឯកឧត្តម ស្វាយ ស៊ីថា អនុរដ្ឋលេខាធិការអមទីស្តីការគណៈរដ្ឋមន្ត្រី ជាអគ្គលេខាធិការ

-ឯកឧត្តម ព្រំ សំអុល ជាអគ្គលេខាធិការរង មានឋានៈស្មើអគ្គនាយករង

-ឯកឧត្តម ខៀវ ឆេង ជាអគ្គលេខាធិការរង មានឋានៈស្មើអគ្គនាយករង

ជំពូក ២

អវសានប្បញ្ញត្តិ

មាត្រា ៣ .- បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ .- អនុក្រឹត្យនេះ មានអានុភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

មាត្រា ៥ .- រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង នីតិសម្បទា ព្រមទាំងរដ្ឋមន្ត្រីនៃបណ្តាក្រសួង និងស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

រាជធានីភ្នំពេញ,ថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

អនុក្រឹត្យលេខ ៤៣ អនក្រ.បក

ស្តីពីការបង្កើតក្រុមប្រឹក្សាដោះស្រាយ

គងកំលាំងប្រដាប់អាវុធ

***

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- តាមសំណើរបស់ប្រធាន ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ